នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Nov-2011, 09:24
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលត្រូវកោះហៅក្នុងអំឡុងពេលបីសប្តាហ៍ដំបូងនៃសវនាការ ជាមួយនឹង ឧបសម្ព័ន្ធ ក សម្ងាត់

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ

ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

Elisabeth SIMONNEAU FORT
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក សរ សូវាន
លោក Jacques VERGÈS

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

## I. សេចក្តីផ្តើម និង ប្រវត្តិ

១. នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយជូនដល់គ្រប់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ទាក់ទងនឹងសាក្សីដែលត្រូវកោះហៅនៅដំណាក់កាលដំបូងនៃសវនាការ និងការទទួលយកឯកសារផ្សេងៗ ("អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង")[1] ។ ឧបសម្ព័ន្ធ ខ នៃ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងនេះ បានកំណត់អត្តសញ្ញាណបុគ្គលដប់ពីរ (១២) នាក់ ដែលត្រូវកោះហៅក្នុងដំណាក់កាលដំបូងនៃសវនាការ នៅចន្លោះថ្ងៃទី២៨ ខែវិច្ឆិកា និងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ ។ ការណ៍នេះមានរាប់បញ្ចូលជនសង្ស័យបួននាក់ ដើមបណ្តឹងរដ្ឋប្បវេណីបីរូប និងសាក្សីប្រាំរូប[2] ។ អនុស្សរណៈនេះបានបង្គាប់ឱ្យ "ភាគីបង្ហាញនូវឯកសារ និងវត្ថុតាងផ្សេងៗពីបញ្ជីដំបូងរបស់ខ្លួន ដែលមានបំណងចង់ឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងសាក្សី និងជំនាញទាំងឡាយដែលនឹងត្រូវកោះហៅនៅក្នុងរយៈពេលបីសប្តាហ៍ដំបូងនៃសវនាការជំនុំជម្រះ មិនឱ្យហួសពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១"[3] ។ អនុស្សរណៈបានណែនាំឱ្យគូភាគីដាក់ការជំទាស់ណាមួយទៅនឹងបញ្ជីឯកសារថ្មីរបស់ភាគីដែលប្រឆាំង ក្នុងរយៈពេល១០ថ្ងៃបន្ទាប់ពីថ្ងៃជូនដំណឹង ។

២. សហព្រះរាជអាជ្ញា សូមរំលឹកថា នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១[4] យោងតាម *ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ* របស់អង្គជំនុំជម្រះ ចេញថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១[5] សហព្រះរាជអាជ្ញា បានដាក់បញ្ជីឯកសាររបស់ខ្លួនដែលក្នុងនោះ បានកំណត់អត្តសញ្ញាណឯកសារមួយចំនួនដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅពេលសវនាការជំនុំជម្រះ ។ សំណៅទីពីរនៃបញ្ជីឯកសារនេះ ត្រូវបានដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[6] ទៅតាមសេចក្តីណែនាំបន្ថែមរបស់អង្គជំនុំជម្រះ[7] ("បញ្ជីឯកសារដំណាក់ដំបូង") ។ បញ្ជីឯកសារដំណាក់ដំបូងនេះ បានកំណត់អត្តសញ្ញាណឯកសារពាក់ព័ន្ធនឹងប្រធានបទចំនួនបួន ដែលបានកំណត់ដោយអង្គជំនុំជម្រះដែលត្រូវគ្របដណ្តប់ក្នុងដំណាក់កាលដំបូងនៃការជំនុំជម្រះ មានជាអាទិ៍៖

(ក) របនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ ។

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ជូនដល់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ស្តីពី បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 (បានបញ្ជូនក្រៅផ្លូវមកៅភាគីនានានៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១) ("អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង") ។

[2] ឧបសម្ព័ន្ធ ខ សម្ងាត់ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ។

[3] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង, ទំព័រទី១ ។

[4] **E9/31** បញ្ជីឯកសារសម្រាប់សវនាការជំនុំជម្រះរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣)នៃវិធានផ្ទៃក្នុង, ១៩ មេសា ២០១១។

[5] **E9** ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ របស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ។

[6] **E109/4** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទងនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ២២ កក្កដា ឆ្នាំ២០១១ ។

[7] **E1/4.1** ប្រតិចារឹកនៃសវនាការបឋម, ២៧ មិថុនា ២០១១, ទំព័រទី២៥ ។

(ខ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅក្នុងអម្លុងពេលមុនការបង្កើតកម្ពុជាប្រជាធិតេយ្យ រួមទាំងនៅពេលដែលតួនាទីទាំងនេះត្រូវបានចាត់តាំង ។

(គ) តួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិតេយ្យ ការទទួលខុសត្រូវតាមការចាត់តាំងរបស់ពួកគេ វិសាលភាពនៃសិទ្ធិអំណាចរបស់ពួកគេ និងខ្សែសង្វាក់នៃការប្រាស្រ័យទាក់ទងគ្នានៅទូទាំងរយៈពេលទាំងមូលដែល អ.វ.ត.ក កំពុងតែយកចិត្តទុកដាក់; ហើយនិង

(ឃ) គោលនយោបាយនានារបស់កម្ពុជាប្រជាធិបតេយ្យ ស្តីពីបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[8] ។

## II. ឯកសារដែលជាប់ទាក់ទងនឹងសាក្សីប្រាំរូប និងដើមបណ្តឹងរដ្ឋប្បវេណីបីរូបដំបូង

៣. ដើម្បីឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញាសូមជូនដំណឹងថា សហព្រះរាជអាជ្ញា នឹងស្វែងរកឱ្យមានការទទួលយកឯកសារនានាដែលបានកំណត់នៅក្នុង **ឧបសម្ព័ន្ធ ក**[9] ដែលជាប់ទាក់ទងនឹងសាក្សីប្រាំរូប និងដើមបណ្តឹងរដ្ឋប្បវេណីបីរូប ដែលបានកោះហៅមកផ្តល់សក្ខីកម្មក្នុងរយៈពេលបីសប្តាហ៍ដំបូងនៃសវនាការ ។ បញ្ជីនេះតំណាងឱ្យកិច្ចខិតខំប្រឹងយ៉ាងខ្លាំងក្លារបស់សហព្រះរាជអាជ្ញា ក្នុងការកំណត់អត្តសញ្ញាណឯកសារចេញពីឯកសារដំណាក់កាលដំបូងរបស់ខ្លួន ដែលស្វែងរកឱ្យទទួលយកជាភស្តុតាងជាប់ទងនឹងបុគ្គលទាំងនេះ ។ ប៉ុន្តែ ដោយសារសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះមិនត្រូវបានស្តាប់ចម្លើយដោយសហព្រះរាជអាជ្ញា - ដើម្បីកំណត់អំពីវិសាលភាពនៃចំណេះដឹងរបស់ពួកគេ អំពីឯកសារនានានៅក្នុងសំណុំរឿង - សហព្រះរាជអាជ្ញា មិនអាចទាយទុកនៅក្នុងដំណាក់កាលនេះឱ្យបានជាក់លាក់ជាងនេះទេ នូវឯកសារបន្ថែមដែលសហព្រះរាជអាជ្ញាអាចនឹងស្វែងរកដើម្បីឱ្យទទួលយកនោះ រហូតទាល់តែបានស្តាប់សក្ខីកម្មរបស់ពួកគាត់សិន ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូង និងគូភាគីនានាត្រូវបានជូនដំណឹងបន្ថែមថា ដោយសារការជាប់ទាក់ទងជាមួយនឹងបុគ្គលទាំងនេះ សហព្រះរាជអាជ្ញាអាចស្វែងរកឱ្យមានការទទួលយកឯកសារដទៃទៀត ដែលបានកំណត់អត្តសញ្ញាណពីមុនរួចហើយនៅក្នុងបញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួន ។

[8] **E1/4.1** ប្រតិចារឹកនៃសវនាការបឋម, ២៧ មិថុនា ២០១១, ទំព័រទី៥ ។

[9] ឯកសារក្នុង**ឧបសម្ព័ន្ធ ក** ទាំងអស់ មាននៅក្នុងបញ្ជីឯកសារដំណាក់កាលដំបូង (ឯកសារ E109/4.9) លើកលែងតែឯកសារ៩ ដូចដូចតទៅនេះក្នុង**ឧបសម្ព័ន្ធ ក** ដែលមានលេខ 85 (D22/43, D22/43.2), 86 (D22/42, D22/42.3), 87 (D22/3605), 171, 735 (D159/5.18), 911 (D108/26.271), 924, 928 and 971 (D232/59.1) ។ ក្នុងចំណោមឯកសារទាំងនេះ មានឯកសារបី មិនទាំងមាននៅក្នុងសំណុំរឿងនៅឡើយគឺ លេខ 171 (ជីវប្រវត្តិសម័យកម្ពុជាប្រជាធិបតេយ្យរបស់ ឡុង នរិន្ទ) (កំណត់ហេតុស្តាប់របស់ សេង សឿន ផ្តល់ជូន DC-Cam); លេខ 924 និង លេខ 928 (កំណត់ហេតុរបស់ វចឹម ទន់ ហៅ ភី ភួន ផ្តល់ជូន DC-Cam) ។

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ*

## III. ឯកសារដែលជាប់ទងនឹងនឹង ជនជាប់ចោទ

៤. បច្ចុប្បន្ននេះ គេមិនដឹងថាតើ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ នឹងចូលបំភ្លឺក្នុងសវនាការនេះដែរឬអត់ ។ មេធាវីការពារក្តី អៀង សារី បានជម្រាប់ជូនអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីការចេញអនុស្សរណៈថា អៀង សារី មានចេតនាប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួនមិនផ្តល់សក្ខីកម្មនៅក្នុងពេលសវនាការទេ[10] ។ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ និងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ត្រូវបង្គាប់ទៅជនជាប់ចោទឱ្យផ្តល់សេចក្តីជូនដំណឹងថា តើពួកគេនឹងចូលបំភ្លឺក្នុងពេលសវនាការដែរឬទេ[11] ។ ក្នុងចម្លើយតបរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សហព្រះរាជអាជ្ញា និងគូភាគីដទៃទៀត ត្រូវបានជូនដំណឹងថា ជនជាប់ចោទមានសិទ្ធិឆ្លើយតបទៅនឹងសំណួរផ្សេងៗបាននៅពេលសវនាការ ហើយទន្ទឹមនេះ ភាគីទាំងអស់គួរតែរៀបចំខ្លួនសម្រាប់ការសួរដេញដោល ។

៥. ដោយសំអាងថា ជនជាប់ចោទម្នាក់ ឬលើសពីនេះ ផ្តល់សក្ខីកម្មនៅក្នុងរយៈពេលបីសប្តាហ៍ដំបូងនៃសវនាការ ទោះបីជាមិនបានស្នើដោយអង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងគូភាគីនានាថា សហព្រះរាជអាជ្ញាអាចស្វែងរកដើម្បីឱ្យទទួលយកឯកសារណាមួយ ដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួនដែលជាប់ទាក់ទងនឹងជនជាប់ចោទទាំងនេះ ។ ដូចបានថ្លែងនៅក្នុង *ដីកាកំណត់ពេលសវនាការ*[12] និង *សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង(ឯកសារ E124/2) និងសំណើពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ*[13] ក្នុងសវនាការដំបូងដែលថាជនជាប់ចោទត្រូវតែតទល់នឹងការចោទប្រកាន់ទាំងអស់ដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២ ។ ជាពិសេស ដោយហេតុថា ឯកសារទាំងនេះបញ្ជាក់បំភ្លឺថា អង្គជំនុំជម្រះសាលាដំបូងរំពឹងទុកថាសវនាការដំបូង "នឹងផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់បទចោទប្រកាន់ទាំងអស់ រួមទាំងបទចោទដែលនឹងត្រូវយកមកពិនិត្យនៅពេលក្រោយ" ។

---

[10] លិខិតពីក្រុមមេធាវីការពារក្តី អៀង សារី ជូន Susan Lamb, មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់នៃអង្គជំនុំជម្រះសាលាដំបូង, ២១ តុលា ២០១១ ។

[11] **E101/5** ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ (ឯកសារ E101 និង E101/1, ២៧ តុលា ២០១១ ។

[12] **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២, ១៨ តុលា ២០១១ ។

[13] **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា អំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ១៨ តុលា ២០១១ ។

*សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អវតក/អជសង*

៦. លើសពីនេះ សន្មតថា មានជនជាប់ចោទម្នាក់មកបំភ្លឺនៅក្នុងរយៈពេលបីសប្តាហ៍ដំបូងនៃសវនាការ ប៉ុន្តែគេមិនដឹងថា តើជនជាប់ចោទនោះនៅពេលក្រោយមក នឹងប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅក្នុងពេលវគ្គ (ឬសវនាការ) បន្ថែមណាមួយទេ ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញានឹងតម្រូវឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ នូវឯកសារណាមួយដែលបានផ្តល់រួចហើយនៅក្នុងបញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួនដើម្បីធានាថា គោលបំណងរបស់អង្គជំនុំជម្រះសម្រាប់សវនាការដំបូងត្រូវបានបំពេញ ។

## IV. ឯកសារដែលត្រូវដាក់ជូនដោយផ្ទាល់នៅ អង្គជំនុំជម្រះសាលាដំបូង

៧. បន្ថែមលើឯកសារដែលត្រូវដាក់ជូនជាប់ទាក់ទងនឹងសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ សហព្រះរាជអាជ្ញាក៏សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងផងដែរថា សហព្រះរាជអាជ្ញា នឹងស្វែងរកដើម្បីដាក់ឯកសារពាក់ព័ន្ធផ្សេងទៀតជូនអង្គជំនុំជម្រះសាលាដំបូងដោយអនុលោមតាមវិធាន៨៧(២) នៃវិធានផ្ទៃក្នុង ។ វិធីសាស្ត្របំពេញបង្គ្រប់ស្តីពីការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះនេះ នឹងធានាបានថា កិច្ចដំណើរការនីតិវិធីប្រព្រឹត្តិទៅឆាប់រហ័ស និងថាភស្តុតាងសក្ខីកម្ម មិនអូសបន្លាយពេលមិនចាំបាច់តាមការបង្ហាញឯកសារមួយចំណែកម្តងៗពីចំនួនឯកសាររបស់បុគ្គលម្នាក់ៗតាមរយៈសក្ខីកម្មផ្ទាល់មាត់នោះទេ ។ វិធីសាស្ត្រនេះ ក៏នឹងជួយផងដែរក្នុងការធានាថា សាក្សីមិនចាំបាច់នឹងមិនត្រូវបានកោះហៅមកបញ្ជាក់អំពីបញ្ហាដែលបានបញ្ជាក់រួចហើយនៅក្នុងខ្លឹមសារនៃឯកសារដែលមានប្រភពដ៏ចំបង ដែលបានទទួលយករួចហើយនោះឡើយ ។ សំណើដាក់ឯកសារជូនអង្គជំនុំជម្រះសាលាដំបូងដោយផ្ទាល់នេះ គឺជាប្រធានបទនៃញត្តិស្នើសុំមួយដែលនឹងត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូងក្នុងពេលដ៏ខ្លីខាងមុខនេះ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១ | លោក William SMITH<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |